ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
លេខ...១៦៤១....កកន

**សូមគោរពជូន**
**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ**

**កម្មវត្ថុ** ៖ របាយការណ៍លទ្ធផល នៃកិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅខេត្តព្រះសីហនុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ នាងខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់នូវរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំដូចខាងក្រោម ៖

អនុលោមតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ និងផែនការសកម្មភាពប្រឆាំងការជួញដូរមនុស្សអនុតំបន់មេគង្គលើកទី៤ ឆ្នាំ២០១៥-២០១៨ លោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារខមមីតកម្ពុជា បានដឹកនាំគណៈប្រតិភូអន្តរក្រសួង ស្ថាប័នតំណាងខេត្តជាប់ព្រំដែនជាមួយវៀតណាមចំនួន៧ និងអង្គការដៃគូសរុបចំនួន៥៩រូប ស្រី៣២រូប ទៅចូលរួមប្រជុំកិច្ចខាងលើ ជាមួយគណៈប្រតិភូនៃសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន២១រូប ស្រី៣រូប ដឹកនាំដោយឯកឧត្តមបណ្ឌិតឧត្តមសេនីយ៍ត្រី ង្វៀន ផុងហ័រ អគ្គនាយករងនៃអគ្គនាយកដ្ឋាននគរបាល ក្រសួងសន្តិសុខសាធារណៈ និងជាអនុប្រធានក្រុមការងារខមមីតវៀតណាម នៅសណ្ឋាគារ New Hill Resort & Spa ខេត្តព្រះសីហនុ ។ កិច្ចប្រជុំបានការគាំទ្រថវិកាមួយផ្នែកធំពីអង្គការ UN-ACT, UNICEF, IOM, USAID/Winrock International, AAPTIP, Rattanak International, Cambodia Acts, Child Fund និង AFESIP ។

កិច្ចប្រជុំស្ថិតក្រោមអធិបតីភាពលោកជំទាវ សាន្ត អរុណ និងឯកឧត្តមបណ្ឌិតឧត្តមសេនីយ៍ត្រី ង្វៀន ផុងហ័រ ក្នុងគោលបំណងពិនិត្យឡើងវិញលើការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការទ្វេភាគី ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម ឆ្នាំ២០១១-២០១៥ និងកសាងផែនការសកម្មភាពរួមជាអាទិភាពសម្រាប់ឆ្នាំ២០១៧-២០១៨ ។

**លទ្ធផលសំខាន់ៗក្នុងកិច្ចប្រជុំរយៈពេល២ថ្ងៃរួមមាន ៖**

-កិច្ចស្វាគមន៍យ៉ាងកក់ក្តៅរបស់ឯកឧត្តម យន្ត មីន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ចំណាប់អារម្មណ៍ដៃគូអភិវឌ្ឍន៍ UN-ACT ថ្នាក់តំបន់ សុន្ទរកថារបស់ប្រធានគណៈប្រតិភូ

ផ្លូវត្រុងមាន ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩
ទូរសារ : ០២៣ ៨៨០ ៧៣៧

វៀតណាម និងសុន្ទរកថាបើករបស់លោកជំទាវប្រធានគណៈប្រតិភូកម្ពុជា សុទ្ធតែបង្ហាញពីការអបអរសាទរ និងគាំទ្រចំពោះសារៈសំខាន់នៃកិច្ចប្រជុំ និងការប្ដេជ្ញាចិត្តបន្តចូលរួមអនុវត្តនូវរាល់ខ្លឹមសារដែលសម្រេចបានក្នុងកិច្ចប្រជុំរយៈពេល ២ថ្ងៃនេះ សំដៅរួមចំណែកកាត់បន្ថយ និងឈានទៅលុបបំបាត់ជាបណ្តើរៗការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាពនៅកម្ពុជា និងវៀតណាម ។

-លទ្ធផលសរុបនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីប្រឆាំងអំពើជួញដូរមនុស្សពីឆ្នាំ២០១១-២០១៥ ការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ (SOPs) ទាំងភាគីកម្ពុជា និងវៀតណាម ព្រមទាំងការសិក្សាស្រាវជ្រាវពីការអនុវត្ត SOPs បានបង្ហាញពីចំណុចល្អក្នុងការអនុវត្ត បញ្ហាប្រឈម និងភាពខ្វះចន្លោះ សំណូមពរក៏ដូចជាអនុសាសន៍មួយចំនួន សម្រាប់ការអនុវត្តបន្តឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

-ការពិនិត្យ ពិភាក្សា និងការឯកភាពលើការកសាងផែនការសកម្មភាពជាអាទិភាពរួមសម្រាប់ឆ្នាំ២០១៧-២០១៨ ដែលផ្តោតជាសំខាន់លើការងារចម្បងៗចំនួន ៥ផ្នែកដូចជា ៖ កិច្ចសម្របសម្រួលដើម្បីអនុវត្តកិច្ចព្រមព្រៀង - ការបង្កើនការយល់ដឹង និងការអប់រំអំពីការជួញដូរមនុស្ស - ការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន SOPs ស្តីពីការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ - ការពង្រឹងការបង្ក្រាប ការចាប់ខ្លួន ការស៊ើបអង្កេត និងការផ្តន្ទាទោសកាត់ទោសឧក្រិដ្ឋជនឆ្លងដែនរវាងកម្ពុជា និងវៀតណាម - ការតាមដាន និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង ។ កិច្ចប្រជុំពិនិត្យឡើងវិញលើការអនុវត្តផែនការសកម្មភាពជាអាទិភាពរួម នឹងប្រព្រឹត្តទៅនៅឆ្នាំ២០១៨ នៅប្រទេសវៀតណាម ។

ចំពោះការពិចារណាលើចំណុចខ្វះខាតនៅក្នុងកិច្ចព្រមព្រៀងដូចជា ការពរពោះជំនួសគេ ការរំលោភបំពាន និងកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធបច្ចេកវិទ្យា អង្គប្រជុំបានសម្រេចរក្សាទុកសម្រាប់ពិភាក្សានៅពេលក្រោយ ។

អង្គប្រជុំបានពិនិត្យ កែសម្រួល និងឯកភាពគ្នាលើកំណត់ហេតុនៃកិច្ចប្រជុំ និងពិធីចុះហត្ថលេខា ដោយលោកជំទាវប្រធានគណៈប្រតិភូកម្ពុជា និងឯកឧត្តមប្រធានគណៈ ប្រតិភូវៀតណាម (គោរពជូនភ្ជាប់នូវកំណត់ហេតុប្រជុំ)។

នៅក្នុងពិធីបិទកិច្ចប្រជុំ ប្រធានគណៈប្រតិភូទាំងពីរបានបញ្ជាក់ច្បាស់ថា ខ្លឹមសារទាំងអស់ដែលបានចុះហត្ថលេខានៅថ្ងៃនេះ គឺជាមូលដ្ឋានដ៏សំខាន់បំផុតក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងវៀតណាម ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយជនរងគ្រោះរបស់ប្រទេសទាំងពីរ ជាពិសេសកិច្ចសហប្រតិបត្តិការរវាងខេត្តជាប់ព្រំដែន ។

កិច្ចប្រជុំបានបញ្ចប់នៅម៉ោង១២:០០ ថ្ងៃត្រង់នៃថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល និងទទួលបានលទ្ធផលល្អ ។ ដោយឡែកចំពោះគណៈប្រតិភូវៀតណាម នៅពេលរសៀល បានធ្វើទស្សនកិច្ចសិក្សានៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងពិសាអាហារសាមគ្គីលាគ្នា ដែលរៀបចំដោយឯកឧត្តម លូ គឹមឈន់ អគ្គនាយកកំពង់ផែ ។ ព្រឹកថ្ងៃទី០៦ខែតុលា

ឆ្នាំ២០១៦ គណៈប្រតិភូបានចាកចេញពីខេត្តព្រះសីហនុ និងចូលទស្សនារមណីយដ្ឋាន បូកគោ ក្នុងខេត្តកំពត ព្រមទាំងវិលត្រឡប់ទៅមាតុប្រទេសវិញដោយសុវត្ថិភាព ក្រោមការជួយអន្តរាគមន៍យ៉ាងល្អពីអាជ្ញាធរដែនដីខេត្តព្រះសីហនុ និងខេត្តកំពត ។

សេចក្តីដូចបានគោរពជម្រាបជូនខាង លើ សូម **សម្តេចក្រឡាហោម** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦

**រដ្ឋលេខាធិការ**

**និងជាប្រធានក្រុមការងារខេមរីតកម្ពុជា**

**គាត អរុណា**

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ
- ខុទ្ទកាល័យលោកជំទាវរដ្ឋមន្ត្រី
- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ
- ឯកឧត្តមអគ្គនាយកកំពង់ផែស្វយ័តព្រះសីហនុ
- គ្រប់សមាជិកចូលរួម
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- ឯកសារ-កាលប្បវត្តិ